**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦២៥ សហវ . ប្រក

# ប្រកាស
# ស្តីពី
# ការណែនាំអនុវត្តការបង់ពន្ធកាត់ទុកលើការប្រាក់ចំពោះប្រាក់ដែលខ្ចីពីបរទេស របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

# សម្រេច

## ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងជួយសម្រាលបន្ទុកចំណាយលើការប្រាក់ចំពោះប្រាក់ដែលខ្ចីពីបរទេសរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីរក្សានិរន្តរភាពនៃវិស័យមីក្រូហិរញ្ញវត្ថុ។

## ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅផ្តល់ការអនុគ្រោះមួយផ្នែកនៃពន្ធកាត់ទុកលើការប្រាក់ចំពោះប្រាក់ដែលខ្ចីពីបរទេសរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

## ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.- ការអនុគ្រោះពន្ធកាត់ទុក

អនុលោមតាមមាត្រា២៦ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ពន្ធកាត់ទុកលើការប្រាក់ចំពោះប្រាក់ដែលខ្ចីពីបរទេសត្រូវអនុវត្តតាមអត្រា ១៤ ភាគរយ ក្នុងនោះ ÷

១- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវអនុវត្តការកាត់ទុកប្រាក់ពន្ធចំនួន ១០ ភាគរយ ពីការប្រាក់ដែលបានទូទាត់ទៅឱ្យអ្នកជាប់ពន្ធអនិវាសនជន។

២- ពន្ធកាត់ទុកលើការប្រាក់ចំនួន ៤ ភាគរយទៀត ត្រូវចាត់ទុកជាបន្ទុករបស់រដ្ឋដើម្បីជាការឧបត្ថម្ភគាំទ្រដល់វិស័យមីក្រូហិរញ្ញវត្ថុ។

ការអនុគ្រោះដូចមានចែងក្នុងប្រការនេះ ត្រូវអនុវត្តចំពោះការទូទាត់ការប្រាក់ ក្នុងអំឡុងឆ្នាំ២០១៧ និង២០១៨ ប៉ុន្តែមិនអនុវត្តចំពោះការប្រាក់ដែលបានទូទាត់មុនពេលចូលជាធរមាននៃប្រកាសនេះទេ។

## ប្រការ ៥.- ឯកសារគាំទ្រ

ដើម្បីអនុវត្តតាមខ្លឹមសារដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវមានឯកសារគាំទ្រដូចខាងក្រោម ÷

១- កិច្ចសន្យាខ្ចីប្រាក់ដែលមានការបញ្ជាក់ពីមេធាវីនៃភាគីទាំងសងខាង

២- ឯកសារផ្ទេរប្រាក់ទាក់ទិននឹងកិច្ចសន្យាខ្ចីប្រាក់ និង

៣- កំណត់ត្រាត្រឹមត្រូវនិងច្បាស់លាស់ក្នុងបញ្ជីគណនេយ្យ។

ឯកសារគាំទ្រខាងលើនេះ មិនតម្រូវឱ្យភ្ជាប់ជាមួយលិខិតប្រកាសសារពើពន្ធទេ ប៉ុន្តែត្រូវរក្សាទុកសម្រាប់គោលដៅនៃការធ្វើសវនកម្មពន្ធដារ។

**ប្រការ ៦.- ភារអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧

បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ